SELF DETERMINATION

កម្មវិធីការសំរេចចិត្តដោយខ្លួនឯង (Self-Determination Program, SDP) គឺជាកម្មវិធីស្ម័គ្រចិត្តមួយ ដែលនឹងជួយមនុស្សដែលពិការវឌ្ឍនភាព និងគ្រួសាររបស់គេ ឲ្យមានការត្រួតត្រាថែមទៀត ទៅលើសេវា និងការគាំទ្រដែលគេត្រូវការ ដើម្បីឲ្យបានសំរេចគោលដៅរបស់គេ។ វានឹងផ្តល់ឲ្យគេនូវគំរោងថវិការៀងៗខ្លួន ដើម្បីទិញសេវា និងការគាំទ្រ ដែលគេត្រូវការ ដើម្បីប្រតិបត្តិគំរោងផ្តោតលើបុគ្គលរៀងៗខ្លួនរបស់គេ។

# អ្នកណាខ្លះ

## អ្នកណាខ្លះដែលមានសិទ្ធទទួលៈ

អ្នកចូលរួមក្នុង SDP ត្រូវតែជាអតិថិជននៃមជ្ឈមណ្ឌលភូមិភាគ ត្រូវតែរស់នៅតាមផ្ទះ ឬនៅក្នុងសហគមន៍ ប៉ុន្តែមិននៅក្នុងមន្ទីរថៃទាំយូរអង្វែង ដើម្បីចូលរួមក្នុងការណែនាំឲ្យស្គាល់ដែលបានយល់ព្រម និងត្រូវសុខចិត្តធ្វើតាមវិន័យខ្លះរបស់កម្មវិធី។

# នៅពេលណា

## វានឹងមាននៅពេលណាៈ

- ក្រសួងសេវាវឌ្ឍនកម្ម (Department of Developmental Services, DDS) បានបញ្ជូនពាក្យសុំទៅរដ្ឋាភិបាលសហព័ន្ធ សំរាប់កម្មវិធីការសំរេចចិត្តដោយខ្លួនឯង។
- បន្ទាប់ពីការដាក់ពាក្យសុំថវិកាពីរដ្ឋបាលសហព័ន្ធត្រូវបានយល់ព្រម SDP នឹងបានប្រតិបត្តិ សំរាប់អ្នកចូលរួម 2,500 នាក់ នៅក្នុងរដ្ឋកាលីហ្វ័រនីញា ក្នុងអំឡុងពេល 3 ឆ្នាំដំបូង។
- ក្នុងអំឡុងពេល 3 ឆ្នាំដំបូងនេះ DDS នឹងជ្រើសរើសអតិថិជន មកពីមជ្ឈមណ្ឌលភូមិភាគនិមួយៗ ឲ្យចូលរួម។
- DDS បានប្រាប់យើង ថាគេនឹងជ្រើសរើសអតិថិជន 98 នាក់ នៃ Harbor Regional Center (HRC) ឲ្យចូលរួមក្នុង DDS ក្នុងអំឡុងពេល 3 ឆ្នាំដំបូង។
- បន្ទាប់ពីដំណាក់ការ-រយៈពេលបីឆ្នាំមក កម្មវិធីនេះនឹងមានសំរាប់អតិថិជន ទាំងអស់ដែលមានចំណង់។

# ដំណើរការ

## ព័ត៌មាន និងដំណើរការជ្រើសរើសៈ

- ក្រសួងសេវាវឌ្ឍនកម្ម និងក្រុមការងាររបស់ខ្លួន កំពុងតែបង្កើតសំភារៈសំរាប់ការហ្វឹកហ្វឺន និងការណែនាំឲ្យស្គាល់។
- កាលណាការផ្តល់ថវិកាពីរដ្ឋបាលសហព័ន្ធត្រូវបានយល់ព្រម ហើយក៏មានសំភារៈទាំងនេះ HRC នឹងអញ្ជើញអតិថិជន និងគ្រួសារដែលមានចំណង់ ឲ្យចូលរួមក្នុង កិច្ចប្រជុំ SDP ផ្តល់ព័ត៌មានមុនការចុះឈ្មោះ (SDP Pre-Enrollment Informational Meeting)។
- បន្ទាប់ពីកិច្ចប្រជុំផ្តល់ព័ត៌មានមុនការចុះឈ្មោះមក អតិថិជន/គ្រួសារដែលមានចំណង់ អាចនឹងស្នើថាគេ គួរតែបានពិចារណាសំរាប់ការចូលរួមក្នុង SDP។
- HRC នឹងបញ្ជូនឈ្មោះគ្រប់ៗគ្នា ដែលស្នើសុំចូលរួមក្នុង SDP ទៅ DDS។
- DDS នឹងសំរេចថាអ្នកមានចំណង់ណាមួយ នឹងត្រូវបានជ្រើសឲ្យចូលរួម ក្នុងអំឡុងដំណាក់ការ-រយៈពេល 3 ឆ្នាំ។

## តើខ្ញុំអាចបានព័ត៌មានថ្មីៗបំផុត នៅទីណា?

- ចុះឈ្មោះសំរាប់សភាពការណ៍តាមអ៊ីមែល ពី DDS ដោយផ្ញើអ៊ីមែលទៅ **sdp@dds.ca.gov** និងសូមឲ្យបានបញ្ចូលក្នុងបញ្ជីជំរាបសភាពការណ៍
- បញ្ជូនសំណួររបស់អ្នក សំរាប់ HRC ទៅ **selfdetermination@harborrc.org**
- ចុះឈ្មោះដើម្បីទទួលសភាពការណ៍ ក្នុងអ៊ីសំបុត្រ HRC ដោយផ្ញើអ៊ីមែលទៅ **enetworksubscriber@harborrc.org** ដោយមានឈ្មោះរបស់អ្នក ឈ្មោះរបស់អតិថិជនបើសិនខុសគ្នា និងអាសយដ្ឋានអ៊ីមែល និងកំណត់ហេតុ ដែលអ្នកចង់ឲ្យបានបន្ថែមទៅក្នុងបញ្ជីព័ត៌មាននៃកម្មវិធីការសំរេចចិត្តដោយខ្លួនឯង នៅ **www.harborrc.org/services/sdp**

HARBOR DEVELOPMENTAL DISABILITIES FOUNDATION, INC.
21231 Hawthorne Boulevard, Torrance, California 90503
www.harborrc.org

HARBOR REGIONAL CENTER

Khmer